# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1237

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : ការពង្រឹងសមត្ថភាពសម្រាប់ជំរុញភាពប្រកួតប្រជែងក្នុងវិស័យដឹកជញ្ជូន និងភស្តុភារកម្មនៅច្រកទ្វារព្រំដែនកម្ពុជា-ថៃ និងកម្ពុជា-វៀតណាម តាមរយៈការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធគាំទ្រឆ្លងកាត់ព្រំដែននៅកម្ពុជា

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/01/25 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 01/01/27 |
| ៣. ចំណាយគម្រោងសរុប | $500,000 |
| ៤. ស្ថាប័នទទួលខុសត្រូវ | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| RESPONSIBLE UNIT | General Department of Logistics |
| អង្គភាពទទួលខុសត្រូវ | អគ្គនាយកដ្ឋានភស្តុភារកម្ម |
| ៥. ស្ថានភាពគម្រោង | គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. |

ព័ត៌មានលម្អិតអំពីគម្រោង

| | |
|---|---|
| ៦. ប្រភេទគម្រោង ៖ | គម្រោងជំនួយបច្ចេកទេស |
| ៧. ប្រភពហិរញ្ញប្បទាន៖ | ស្វែងរកម្ចាស់ជំនួយ |

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៤- ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

ការអភិវឌ្ឍធនធានមនុស្សនិងការពង្រឹងស្ថាប័នតាមរយៈអនុវត្តការងារសម្របសម្រួល និងការរៀនសូត្រដោយការអនុវត្តជាមួយនឹងគម្រោងដែលបានស្នើសុំនេះ។ ការរៀបចំឯកសារ និងរបាយការណ៍នៃការរកឃើញសំខាន់ៗ ដែលជាផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តគម្រោងនៃការណែនាំអំពីប្រព័ន្ធដាក់ចំណាត់ថ្នាក់នៅក្នុងឧស្សាហកម្មភស្តុភារកម្ម ឱ្យមានអំណោយផលបរិស្ថាន និងការប្រកួតប្រជែងដោយយុត្តិធម៌ទៅលើការអភិវឌ្ឍ វិស័យភស្តុភារកម្ម និងសម្រាប់អ្នកផ្តល់សេវាកម្មភស្តុភារកម្ម។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

ឧត្តរមានជ័យ, ស្វាយរៀង, ប៉ៃលិន, ព្រៃវែង, បាត់ដំបង, តាកែវ, កំពត, កោះកុង, បន្ទាយមានជ័យ,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

គម្រោងនេះ មានគោលបំណងធ្វើឱ្យប្រសើរឡើងការដឹកជញ្ជូន និងពាណិជ្ជកម្មឆ្លងកាត់ព្រំដែនអន្តរជាតិ ។
គោលបំណងសំខាន់ៗនៃគម្រោងស្នើសុំនេះ រួមមាន៖
• សិក្សា និងពិនិត្យលើសក្តានុពលនៃច្រកទ្វារព្រំដែន និងទីតាំងដែលមានសក្តានុពលក្នុងការបើកច្រកទ្វារព្រំដែន ថ្មី ដើម្បីបង្កើនការដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែន ក៏ដូចជាទាក់ទាញវិនិយោគពីអន្តរជាតិ
• ពិនិត្យមើលលើ លទ្ធភាពក្នុងការពង្រីកវិសាលភាព នៃច្រកទ្វារព្រំដែន តាមរយៈការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទាំងផ្នែករឹង និងផ្នែកទន់
• ពិនិត្យមើលលើ លទ្ធភាពក្នុងការជំរុញបើកច្រកទ្វារថ្មី ដែលអាចជួយទាក់ទាញពាណិជ្ជកម្មនៅក្នុងតំបន់ រៀបចំផែនការ និងអនុវត្តសាកល្បង នូវការពង្រីកវិសាលភាពនៃច្រកព្រំដែន ផ្អែកតាមរបាយការណ៍ដែលបានសិក្សា។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

គម្រោងនេះ មានគោលបំណងធ្វើឱ្យប្រសើរឡើងការដឹកជញ្ជូន និងពាណិជ្ជកម្មឆ្លងកាត់ព្រំដែនអន្តរជាតិ ដើម្បីជំរុញការអភិវឌ្ឍវិស័យភស្តុភារកម្មនៅប្រទេសកម្ពុជា ជាពិសេសនៅតំបន់ព្រំដែន តាមរយៈការសិក្សាលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្នែកទន់ និងរឹង។ គម្រោងនេះមានធាតុផ្សំសំខាន់រួមមានដូចខាងក្រោម៖
• ការចុះសិក្សា
 - ប្រមូលទិន្នន័យជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីកំណត់នូវចំណុចគន្លឹះ និងសូចនាករសម្រាប់ធ្វើការវាស់វែងលើសក្តានុពលនៃច្រកទ្វារព្រំដែនសំខាន់នៅប្រទេសកម្ពុជា ដែលអាចជាមូលដ្ឋានក្នុងការប្រៀបធៀប និងវិភាគលើសមត្ថភាព និងសក្តានុពលសម្រាប់ច្រកផ្សេងទៀត ដែលនឹងធ្វើការអភិវឌ្ឍបន្ថែមនៅថ្ងៃអនាគត
 - ការចុះពិនិត្យលើទីតាំងជាក់ស្តែង និងទីតាំងភូមិសាស្ត្រនៅតំបន់ច្រកព្រំដែន
 - ការចុះរាប់ស្ថិតិចរាចរនៅច្រកព្រំដែនដែលកំពុងធ្វើដំណើរឆ្លងកាត់ច្រក
• ការរៀបចំរបាយការណ៍សិក្សា
 - រៀបចំសេចក្តីព្រាងរបាយការណ៍សិក្សាការជំរុញភាពប្រកួតប្រជែងក្នុងវិស័យដឹកជញ្ជូន និងភស្តុភារកម្មនៅច្រកទ្វារព្រំដែនកម្ពុជា-ថៃ និងកម្ពុជា-វៀតណាម តាមរយៈការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធគាំទ្រឆ្លងកាត់ព្រំដែន ដែលតម្រូវឱ្យមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទាំងផ្នែកទន់ និងរឹង ដែលគាំទ្រដល់ការអភិវឌ្ឍនៅច្រកព្រំដែន រួមបញ្ចូលទាំងស្តង់ដារបច្ចេកទេសដែលពាក់ព័ន្ធនឹងប្រទេសជិតខាង
 - រៀបចំកិច្ចប្រជុំបច្ចេកទេសជាមួយភាគីពាក់ព័ន្ធដើម្បីប្រមូលនូវព័ត៌មានគ្រប់គ្រាន់ ឬធាតុចូលបន្ថែម
 - កែសម្រួល និងរៀបចំជារបាយការណ៍ចុងក្រោយ
• រៀបចំសិក្ខាសាលា
 - រៀបចំសិក្ខាសាលាផ្សព្វផ្សាយលើរបាយការណ៍សិក្សាជាផ្លូវការទៅកាន់ភាគីពាក់ព័ន្ធ ឬ អាជ្ញាធរ ដើម្បីផ្សព្វផ្សាយនូវគម្រោងអភិវឌ្ឍន ឬបង្កើតនូវហេដ្ឋារចនាសម្ព័ន្ធបន្ថែមដើម្បីពង្រឹងច្រកព្រំដែន ដែលធ្វើប្រសើរឡើងការដឹកជញ្ជូន និងភស្តុភារកម្មឆ្លងកាត់ព្រំដែន ដោយផ្អែកលើរបាយការណ៍សិក្សានេះ។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

• ដោយសារតែមានការបង្កើតក្រុមប្រឹក្សាជាតិភ័ស្តុភារកម្ម និងគណកម្មាធិការជាតិភ័ស្តុភារកម្ម ដែលមានអគ្គ-នាយកដ្ឋានភ័ស្តុភារកម្មជាលេខាធិការដ្ឋាន ជាអ្នកដើរតួយ៉ាងសំខាន់ក្នុងការជម្រុញការអភិវឌ្ឍវិស័យភ័ស្តុភារកម្ម ហើយសមត្ថភាពគ្រប់គ្រងរបស់អគ្គនាយកដ្ឋានភស្តុភារកម្ម តម្រូវឱ្យមានការពង្រឹង សមត្ថភាពបន្ថែម ដើម្បីឱ្យការអនុវត្តការងារប្រកបដោយប្រសិទ្ធិភាព

• ការអភិវឌ្ឍវិស័យភ័ស្តុភារកម្ម ក៏ត្រូវបានដាក់បញ្ចូលក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ២០១៥-២០២៥ របស់រាជរដ្ឋាភិបាល។

• ដោយសេដ្ឋកិច្ចនៃប្រទេសកម្ពុជា មានការកើនឡើងគួរឱ្យកត់សម្គាល់ ការកើនឡើងនៃលំហូរទំនិញ អ្នកដំណើរ និងសេវាកម្ម ក៏មានការរីកចម្រើនខ្លាំងដែរ ពិសេសនៅតាមច្រកព្រំដែន ដែលតម្រូវឱ្យមាននូវហេដ្ឋារចនាសម្ព័ន្ធគាំទ្រដែលមានសមត្ថភាព និងប្រសិទ្ធភាព

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

• ដោយហេដ្ឋារចនាសម្ព័ន្ធមានគុណភាព និងសមត្ថភាព នាំអោយលំហូរពាណិជ្ជកម្មមានការកើនឡើង និងទាក់ទាញនូវវិនិយោគ ដែលជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនៃប្រទេសកម្ពុជា

• សេវាកម្មភ័ស្តុភារកម្ម និងដឹកជញ្ជូនមានការរីកចម្រើន និងមានគុណភាពស្តង់ដារធៀបនឹងប្រទេសជិតខាងដោយសារការជំរុញ និងគាំទ្រពីហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅតាមច្រកព្រំដែន

• ភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធសំខាន់ៗផ្សេងទៀត អាចប្រើរបាយការណ៍លទ្ធផលនៃគម្រោងនេះជាឯកសារជំនួយស្មារតីរបស់ខ្លួនសម្រាប់បម្រើការងារ និងផលប្រយោជន៍ផ្ទាល់ខ្លួននានា

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **គ្មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទាន់ចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌នាសង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងនេះនឹងមិនមានសកម្មភាពណាមួយ ដែលនឹងជះឥទ្ធិពលអវិជ្ជមានដល់សង្គម និង/ឬ បរិស្ថានឡើយ។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

តុល្យភាពយេនឌ័រ និងការបញ្ជ្រាបយេនឌ័រនឹងត្រូវយកចិត្តទុកដាក់នៅក្នុងគម្រោងនេះ។

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**ក្រសួងមានអ្នកជំនាញដែលមានជំនាញនិងបទពិសោធន៍ខ្លះៗ**
**ប៉ុន្តែអ្នកឯកទេសអន្តរជាតិតម្រូវឱ្យមានការជួយផ្ទេរជំនាញនិងចំណេះដឹង**
**ដើម្បីពន្លឿនប្រសិទ្ធភាពនៃការសិក្សាលើសក្តានុពលនៃច្រកទ្វារព្រំដែន និងហេដ្ឋារចនាសម្ព័ន្ធរួបវន្តគាំទ្រ។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

20

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**កំពុងស្វែងរកម្ចាស់ជំនួយ**

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ដាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 20.0 | 20.0 | 20.0 | 60.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារ:និងរដ្ឋបាល | 0.0 | 0.0 | 0.0 | 20.0 | 20.0 | 20.0 | 60.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 150.0 | 150.0 | 140.0 | 440.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 100.0 | 100.0 | 100.0 | 300.0 | 0.0 |
| ទព្វសម្ភារ: | 0.0 | 0.0 | 0.0 | 40.0 | 40.0 | 30.0 | 110.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 10.0 | 10.0 | 10.0 | 30.0 | 0.0 |
| | | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ចំណាយសរុប | 0.0 | 0.0 | 0.0 | 170.0 | 170.0 | 160.0 | 500.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 170.0 | 170.0 | 160.0 | 500.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: